ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..៨៥...០៧១...៤៨១.ធ.ជ..ក

ថ្ងៃអង្គារ ៤កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១

## សេចក្តីជូនដំណឹង
## ការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី៨៥

ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបថា ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី៨៥ ត្រូវដាក់ឱ្យដេញថ្លៃនៅថ្ងៃអង្គារ ៤កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ និងមានថ្ងៃប្រសិទ្ធភាពនៅថ្ងៃព្រហស្បតិ៍ ៦កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១។ ព័ត៌មានពាក់ព័ន្ធនឹងការដេញថ្លៃនេះមានដូចតទៅ៖

- -ពេលវេលាដាក់ដេញថ្លៃ : ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ ១២:០០ ថ្ងៃត្រង់
- -នីតិវិធីដេញថ្លៃ : ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល) និងអត្រាការប្រាក់ដាក់ដេញថ្លៃជាភាគរយ (ពីរខ្ទង់ក្រោយក្បៀស)
- -វត្ថុធានា : NCD ជាវត្ថុធានាត្រូវមានឥណប្រតិទានធំជាង ឬស្មើនឹងឥណប្រតិទានរបស់ LPCO
- -ទំហំទឹកប្រាក់ដេញថ្លៃអប្បបរមា : ២០០.០០០.០០០ (ពីររយលាន) រៀល
- -ទំហំទឹកប្រាក់ដេញថ្លៃអតិបរមា : មិនកំណត់

ទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃ អត្រាការប្រាក់ Haircut លើវត្ថុធានា និងថ្ងៃឥណប្រតិទាន មានដូចតទៅ៖

| ប្រភេទ LPCO | ថ្ងៃឥណប្រតិទាន | ទឹកប្រាក់ដាក់ឱ្យដេញថ្លៃ | អត្រាការប្រាក់ដាក់ដេញថ្លៃអប្បបរមា | Haircut លើ USD-NCD |
|---|---|---|---|---|
| ៩១ថ្ងៃ (D091) | ១៤ តុលា ២០២១ | ៧០.០០០.០០០.០០០ រៀល | ២,១០% | ៣% |
| ១៨២ថ្ងៃ (D182) | ១៣ មករា ២០២២ | ៨០.០០០.០០០.០០០ រៀល | ២,៣០% | ៣% |
| ៣៦៤ថ្ងៃ (D364) | ១៤ កក្កដា ២០២២ | ៥០.០០០.០០០.០០០ រៀល | ២,៥០% | ៣% |

ការដេញថ្លៃត្រូវធ្វើតាមផ្ទៃតហូមធនាគារជាតិនៃកម្ពុជា (NBCP) ក្នុងករណី NBCP មិនអាចអនុវត្តបាន ពាក្យសុំដេញថ្លៃត្រូវបញ្ជូនតាមសារអេឡិចត្រូនិក bod_lpco@nbc.org.kh ឬដាក់ក្នុងស្រោមសំបុត្របិទជិត និងផ្ញើមកនាយកដ្ឋានប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា ឱ្យបានមុនម៉ោង ១២:០០ ថ្ងៃត្រង់ នាថ្ងៃដដែល។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៩២៦ ១១៧

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០ រសៀល នាថ្ងៃដដែល។ គ្រឹះស្ថានដែលដេញថ្លៃឈ្នះត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

គណៈកម្មការដេញថ្លៃរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការ LPCO។

សូមទំនាក់ទំនង ៖
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣ ឬ (៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨
សារអេឡិចត្រូនិក : lpco_info@nbc.org.kh